クメール語

# ការជិះកង់ល្មើសច្បាប់ចរាចរណ៍ នឹងត្រូវពិន័យជាប្រាក់ !

**ចាប់ពីថ្ងៃទី 1 ខែ 4 ឆ្នាំ 2026 ទៅ**

- ប្រសិនជាមិនគោរពវិន័យចរាចរណ៍ស្តីពីការជិះកង់ទេ នោះនឹងទៅជាការល្មើសច្បាប់ចរាចរណ៍។
- កាលបើល្មើសច្បាប់ចរាចរណ៍ នោះនឹងត្រូវបង់ប្រាក់ ដែលជាប្រាក់ពិន័យល្មើសច្បាប់។
- ច្បាប់នេះអនុវត្តចំពោះអ្នកដែលមានអាយុចាប់ពី16 ឆ្នាំឡើងទៅ (អ្នកដែលត្រូវបង់ប្រាក់ពិន័យល្មើសច្បាប់)។



## ប្រភេទជិះកង់ដែលជាការល្មើសច្បាប់ចរាចរណ៍

※ ប្រភេទល្មើសច្បាប់ចរាចរណ៍ជិះកង់ សរុបមាន113ប្រភេទ។ មានប្រភេទល្មើសខ្លះមិនបានសរសេរនៅទីនេះទេ។
※ ប្រសិនជាមានរឿងមិនយល់ សូមសួរទៅអធិការដ្ឋាននគរបាលដែលនៅក្បែរអ្នក។

① 
ការប្រើទូរសព្ទដៃបណ្តើរជិះកង់បណ្តើរគឺជាការល្មើសច្បាប់។
ប្រាក់ពិន័យ ￥12,000

② 
ការមិនបានឈប់បន្តិចសិន ដើម្បីបញ្ជាក់ពីសុវត្ថិភាពនៅមុខផ្លូវរថភ្លើង គឺជាការល្មើសច្បាប់។
ប្រាក់ពិន័យ ￥6,000

③ 
ការមិនគោរពភ្លើងសញ្ញា គឺជាការល្មើសច្បាប់។ អាចទៅមុខបាន តែនៅពេលភ្លើងសញ្ញាមានពណ៌ខៀវប៉ុណ្ណោះ។
ប្រាក់ពិន័យ ￥6,000

④ 
ការជិះកង់នៅខាងស្តាំដៃផ្លូវ គឺជាការល្មើសច្បាប់។
ប្រាក់ពិន័យ ￥6,000

⑤ 

ការមិនបានឈប់បន្តិចសិន ដើម្បីបញ្ជាក់ពីសុវត្ថិភាពនៅកន្លែងដែលមានផ្លាកសញ្ញា『ឈប់』គឺជាការល្មើសច្បាប់។




ប្រាក់ពិន័យ ￥5,000

⑥ 
ការជិះកង់ពាក់កាសស្តាប់ចម្រៀងជាអាទិ៍ ដែលនៅក្នុងស្ថានភាពមិនអាចស្តាប់ឮសំឡេងនៅជុំវិញខ្លួនបាន គឺជាការល្មើសច្បាប់។
ប្រាក់ពិន័យ ￥5,000

⑦ 
ការជិះកង់ដោយបាំងឆ័ត្រ គឺជាការល្មើសច្បាប់
ប្រាក់ពិន័យ ￥5,000

⑧ 
ការជិះកង់ដោយដឹកអីវ៉ាន់ធំៗ គឺជាការល្មើសច្បាប់។
ប្រាក់ពិន័យ ￥5,000

⑨ 
ការជិះកង់មិនបើកភ្លើងនៅពេលយប់ គឺជាការល្មើសច្បាប់។
ប្រាក់ពិន័យ ￥5,000

⑩ 
ការជិះកង់ទន្ទឹមគ្នា គឺជាការល្មើសច្បាប់។
ប្រាក់ពិន័យ ￥3,000

⑪ 
ការជិះកង់ឌុបគ្នា គឺជាការល្មើសច្បាប់។
ប្រាក់ពិន័យ ￥3,000

ប្រសិនជាមានបំពាក់កៅអីសម្រាប់កុមារ អាចឌុបកុមារដែលមានអាយុមុនចូលរៀនបឋមសិក្សាបាន (កុមារអាយុមិនលើសពី 6 ឆ្នាំ)។
អ្នកដែលអាចឌុបបានត្រូវមានអាយុចាប់ពី 16 ឆ្នាំឡើង។
អាចឌុបកុមារបានត្រឹម 2 នាក់ប៉ុណ្ណោះ។



ផ្លាកសញ្ញា


⑫ 
ការជិះលើផ្លូវសម្រាប់អ្នកថ្មើរជើងគឺល្មើសច្បាប់។
ប្រាក់ពិន័យ ￥6,000
អាចជិះលើផ្លូវថ្មើរជើងបាន ក្នុងករណីពី [1]~[3] ដូចខាងក្រោម។
[1] ពេលមានផ្លាកសញ្ញាថាអាចជិះលើផ្លូវថ្មើរជើងក៏បាន។
[2] កុមារអាយុមិនលើសពី12ឆ្នាំ អ្នកមានអាយុចាប់ពី70ឆ្នាំ អ្នកមានពិការភាពរាងកាយ។
[3] ពេលផ្លូវយានយន្តមានរថយន្តបើកច្រើន ពេលទំហំនៃផ្លូវយានយន្តតូចចង្អៀត។

- កាលបើល្មើសច្បាប់ចរាចរណ៍ នឹងត្រូវបានប៉ូលិសហុចសំបុត្រពណ៌ខៀវ(ឯកសារស្តីពីល្មើសច្បាប់ចរាចរណ៍) និងក្រដាសបង់ប្រាក់ពិន័យ។
- យកសំបុត្របង់ប្រាក់ពិន័យទៅបង់នៅធនាគារឬប៉ុស្តិ៍ប្រៃសណីយ៍ជាអាទិ៍ ក្នុងអំឡុងថ្ងៃដែលត្រូវបានកំណត់ នីតិវិធីបង់ប្រាក់នឹងចប់រួចរាល់។
- ប្រសិនជាមិនបានបង់ប្រាក់ពិន័យ នៅក្នុងអំឡុងថ្ងៃដែលត្រូវបានកំណត់ទេ អាចនឹងត្រូវបានកាត់ក្តីដោយតុលាការ។



សំបុត្រពណ៌ខៀវ



ក្រដាសបង់ប្រាក់ពិន័យ

じてんしゃ　るーる　まも　あんぜん
自転車も ルールを守って 安全に！



ぎふけんけいさつ
岐阜県警察

ぎふけん けいさつ こうしき
岐阜県警察公式 Facebook
https://www.facebook.com/GifuPrefecturalPolice